# សិក្ខាសាលាពិគ្រោះយោបល់
# ស្តីពី
# ការកសាងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ
# ក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្ម

នាព្រឹកថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៥ នៅសណ្ឋាគារ CAMBODIANA នាយកដ្ឋានបច្ចេកទេស វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៃអគ្គនាយកដ្ឋានឧស្សាហកម្ម ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានសហការជាមួយ នាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃក្រសួងបរិស្ថាន បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ស្តីពី “**ការកសាងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្ម**” ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ទឹង ស៊ីនី** អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ការធ្វើបទបង្ហាញ ការសម្របសម្រួល នៃកិច្ចពិភាក្សាក្នុងអង្គសិក្ខាសាលានេះត្រូវបានដឹកនាំដោយ **លោក ម៉ែន គៀហាក់** ប្រធាននាយកដ្ឋានបច្ចេកទេស វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។

គោលបំណងសិក្ខាសាលា គឺផ្តោតទៅលើការផ្តល់មតិ ការកែសម្រួល និងការផ្តល់អនុសាសន៍បន្ថែមទៅលើសេចក្តីព្រាង **ការកសាងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្ម** ពីភាគីឯកជន មន្ត្រីជំនាញពាក់ព័ន្ធរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មន្ត្រីនាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃក្រសួងបរិស្ថាន សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា និងដៃគូអភិវឌ្ឍនានា ដែលមានសិក្ខាកាមចូលរួមចំនួន ៤៥ រូប ។

សិក្ខាសាលាបានបញ្ចប់នៅវេលាម៉ោង ១៣: ៣០ នាទីរសៀល នាថ្ងៃខែឆ្នាំដដែលប្រកបដោយការចូលរួមផ្តល់មតិយោបល់ និងការពិភាក្សាយ៉ាងសកម្មពីសមាជិកនៃអង្គសិក្ខាសាលាទាំងមូល។





